អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងហេតុអ្វីបានជាយើងលង់ទឹក?**

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖
ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងសាច់ដុំដៃនិងសាច់ដុំភ្នែក៖

**វិទ្យាសាស្ត្រ** ៖ ការរស់នៅប្រចាំថ្ងៃ៖ ការស្វែងយល់ដោយការសង្កេត៖

**សិក្សាសង្គម** ៖ គំនូរនិងសកម្មភាពកសាង៖
ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតជារូបភាព៖

**គោលបំណង៖**

**ចិត្តចលភាព** ៖ វិជ្ជាសម្បទា ៖ ប្រាប់បានពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗ
ដោយការធ្វើអ្វីមួយឬលេងល្បែងមួយ។
ចរិយាសម្បទា ៖ មានអំណត់ ការតស៊ូនិងសប្បាយរីករាយក្នុងពេលធ្វើអ្វីមួយ
ឬលេងល្បែងអ្វីមួយបានរឹងមាំល្អនិងជោគជ័យ។

**វិទ្យាសាស្ត្រ** ៖ វិជ្ជាសម្បទា៖ ប្រាប់បានពីរបៀបនៃការពិសោធន៍និងស្វែងយល់បរិស្ថាន។
បំណិនសម្បទា៖
ពិសោធន៍និងស្វែងយល់ដោយប្រើប្រាស់សម្ភារផ្សេងៗក្នុងការលេងដូចជា៖ ការលិច
អណ្តែត ជ្រាបទឹក មិនជ្រាបទឹក វត្ថុរលាយ និងមិនរលាយ ការលាយពណ៌
បណ្តុះគ្រាប់ធញ្ញជាតិនិងខ្យល់ជាដើម។

**សិក្សាសង្គម** ៖ វិជ្ជាសម្បទា៖ បត់ក្រដាសបានជារូបភាពផ្សេងៗ៖ យន្តហោះ ទូក អាវ ភ្នែក…
ចរិយាសម្បទា៖ រហ័សរហួន និងប្រុងប្រយ័ត្នក្នុងការការចាប់កាន់ បត់ សូន គូស
ហែក កាត់ និងផាត់ពណ៌។

**កម្រិតសិក្សា** ៖ទាប មធ្យមនិង ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាស កន្ត្រៃ ទុយោរ រូបច្រមុះ រូបមាត់ កាវ ស្កុត ដីខ្មៅ ហ្វឺត

**ការរៀបចំ** ៖ រៀបចំសម្ភារដែលត្រូវត្រៀមក្នុងការលេងធ្វើ ឬធ្វើវាឱ្យរួច

**សេចក្តីណែនាំ** ៖

1. សួរកុមារថា តើកូនៗចេះហែលទឹកអត់?
   មានអ្នកណាដែលបង្រៀនកូនៗឱ្យចេះហែលទឹកអត់? កូនៗដែលលង់ទឹកអត់?
2. ថ្ងៃនេះគ្រូនឹងមកប្រាប់កូនៗថា ហេតុអ្វីបានជាយើងលង់ទឹក?
   (ពេលយើងមិនចេះហែលទឹក នៅពេលដែលយើងលិចចូលទៅក្នុងទឹក
   យើងត្រូវការដកដង្ហើមដែរ តែពេលដែលយើងដកដង្ហើមក្នុងទឹក
   ទឹកនឹងចូលទៅដល់សួតរបស់យើង វាធ្វើឱ្យយើងពិបាកដកដង្ហើមបន្តទៀត
   ហើយនៅពេលដែលយើងមិនអាចដកដង្ហើមបន្តទៀតបានយើងអាចនឹងស្លាប់នៅក្នុងទឹកនោះ
   តែម្តង) គ្រប់យ៉ាងបណ្តាលមកពីយើងមិនចេះហែលទឹកហ្នឹងឯង។
3. បន្ទាប់មកបង្ហាញកុមារពីដំណើរការសួតដែលអ្នកបានធ្វើរួច ជាការពិសោធន៍ផងដែរ។
4. ប្រាប់កុមារពីរបៀបធ្វើរូបសួតនិងការពិសោធន៍ថាពេលយើងដកបង្ហើមទៅ
   សួតរបស់យើងនឹងមានសភាពបែបណា ជាមុនសិនះ
   - កាត់ក្រដាសធ្វើជារាងសួតចំនួន២បន្ទះ (គូរជារាងសួតដោយខ្លួនឯងបាន)
   - គូរធ្វើរូបរាងដូចជាសួត
   - លាបកាវជុំវិញ (ដោយមិនចាំបាច់លាបត្រង់ចំណុចកណ្តាលនិងត្រង់ផ្នែកខាងលើនៃទងសួត។
   - ហើយចាប់ផ្តើមបិទភ្ជាប់គ្នា(ទុកឱ្យស្ងួត)
   - បិទទុយោរផ្គោបភ្ជាប់គ្នា២ស៊កចូលទៅក្នុងសួតត្រង់ចំណុចទងសួតនិងញែកទុយោរជាពីរ។
   - បិទទុយោរឱ្យទៅនឹងសួតកុំឱ្យមានខ្យល់ចេញនៅពេលផ្លុំ។
   - បន្ទាប់មកបិទមាត់និងច្រមុះ ជាការស្រេច។